ក្រសួងអប់រំ យុវជន និងកីឡា
សាកលវិទ្យាល័យចំរើនពហុបច្ចេកវិទ្យា
មហាវិទ្យាល័យ នីតិសាស្ត្រ

នុ ថារិទ្ធ

# ការការពារស្របច្បាប់

និក្ខេបបទអនុបណ្ឌិតនីតិសាស្ត្រ

ជំនាញឯកទេស : នីតិសាស្ត្រ

ភ្នំពេញ.២០០៤

អំណោយ
បណ្ឌិត ខុត ធីតា

ក្រសួងអប់រំ យុវជន និងកីឡា
សាកលវិទ្យាល័យចំរើនពហុបច្ចេកវិទ្យា
មហាវិទ្យាល័យ នីតិសាស្ត្រ

នូ ថារិទ្ធ

# ការការពារស្របច្បាប់

និក្ខេបបទអនុបណ្ឌិតនីតិសាស្ត្រ

ជំនាញឯកទេស : នីតិសាស្ត្រ

ព្រះរាជាណាចក្រកម្ពុជា
លេខ 0011964-
រាជបណ្ឌិត្យសភាកម្ពុជា

សាស្ត្រាចារ្យណែនាំនិក្ខេបបទ :
បណ្ឌិត ស៊ិន រិទ្ធ

ភ្នំពេញ-២០០៤

# មាតិកា


| | ទំព័រ |
|---|---|
| សេចក្ដីថ្លែងអំណរគុណ | I |
| អក្សរកាត់ | II |
| មាតិកា | IV |
| លំនាំដើម | VI |
| សេចក្ដីផ្ដើម | IX |
| **ជំពូកទី១** | |
| **ការការពារខ្លួនស្របច្បាប់ ឬ កិច្ចការពារជាធម្មានុរូប** | |
| **១.១-អត្ថន័យទូទៅនៃការការពារខ្លួនស្របច្បាប់ ឬ កិច្ចការពារជាធម្មានុរូប** | ១ |
| ១.១.១-និយមន័យ | ១ |
| ១.១.២-គ្រឹះនៃយុត្តិកម្ម | ៤ |
| **១.២-ល័ក្ខខ័ណ្ឌនៃការការពារខ្លួនស្របច្បាប់ ឬ កិច្ចការពារជាធម្មានុរូប** | ៥ |
| ១.២.១-ល័ក្ខខ័ណ្ឌនៃការការពារខ្លួនស្របច្បាប់ចំពោះមនុស្ស | ៥ |
| -ល័ក្ខខ័ណ្ឌតាមទ្រឹស្ដីនីតិព្រហ្មទណ្ឌ | ៥ |
| -ល័ក្ខខ័ណ្ឌតាមច្បាប់ព្រហ្មទណ្ឌ | ៦ |
| ក-ល័ក្ខខ័ណ្ឌធ្វើឱ្យកកើតសិទ្ធិការពារស្របច្បាប់ | ៧ |
| ក.១-អំពើរំលោភបំពាន | ៨ |
| ក.២-អំពើរំលោភបំពានកំពុងស្ដែងឡើង | ១៨ |
| ខ-ល័ក្ខខ័ណ្ឌអំពីចរិតស្របច្បាប់នៃអំពើតទល់ | ២០ |
| ខ.១-អំពើតទល់ជានីត្យានុកូល | ២១ |
| ខ.២-តុល្យភាពនៃអំពើតទល់ | ២៩ |
| ១.២.២-ល័ក្ខខ័ណ្ឌនៃការការពារស្របច្បាប់ចំពោះទ្រព្យសម្បត្តិ | ៣១ |
| **១.៣-ការការពារក្នុងករណីធ្វើទុក្ខបុកម្នេញ** | ៣៤ |
| **១.៤-ប្រៀបធៀបល័ក្ខខ័ណ្ឌនៃការការពារស្របច្បាប់ចំពោះមនុស្ស និង ចំពោះទ្រព្យសម្បត្តិ** | ៣៨ |
| ក-ភាពដូចគ្នា | ៣៨ |

ខ-ភាពខុសគ្នា ៣៨

## ជំពូកទី២

## ស្ថានភាពចាំបាច់

**២.១-អត្ថន័យទូទៅនៃស្ថានភាពចាំបាច់** ៣៩

២.១.១-និយមន័យ ៣៩

២.១.២-គ្រឹះនៃស្ថានភាពចាំបាច់ ៤២

**២.២-លក្ខខណ្ឌនៃស្ថានភាពចាំបាច់** ៤៣

-លក្ខខណ្ឌតាមទ្រឹស្តីនីតិព្រហ្មទណ្ឌ ៤៣

២.២.១-លក្ខខណ្ឌអំពីការកកើតឡើងនូវស្ថានភាពចាំបាច់ ៤៣

ក-ករណីនៃប្រធានសក្តិ ៤៤

ក.១-ព្រឹត្តិការណ៍ដែលបណ្តាលមកពីគ្រោះធម្មជាតិ ៤៤

ក.២-ព្រឹត្តិការណ៍ដែលមិនអាចទប់ទល់បាន ៤៦

-ការបង្ខិតបង្ខំ ៤៦

-បច្ចេកទេស ៤៩

-ការភាន់អង្គហេតុ ៥០

-តំណាងអយ្យការមិនបានបង្ហាញពីធាតុសត្យានុម័តនៃបទល្មើស ៥១

-ការទទួលរងគ្រោះដោយថៃដន្យ ៥២

-ការធ្វើអត្តឃាត ៥៣

-ជនខ្វះការពិចារណា ឬ អនីតិជន ៥៦

-ជនវិកលចរិត ៥៩

២.២.២-លក្ខខណ្ឌអំពីចរិតស្របច្បាប់នៃអំពើប្រព្រឹត្តក្នុងស្ថានភាពចាំបាច់ ៦៨

**២.៣-ប្រៀបធៀបការការពារស្របច្បាប់ និង ស្ថានភាពចាំបាច់** ៧១

ក-ភាពដូចគ្នា ៧១

ខ-ភាពខុសគ្នា ៧១

**សេចក្តីសន្និដ្ឋាន** ៧៣

# លំនាំដើម

និក្ខេបបទនេះ គឺជានិក្ខេបបទបញ្ចប់ការសិក្សាថ្នាក់អនុបណ្ឌិតនៅសាកលវិទ្យាល័យចំរើនពហុបច្ចេកវិទ្យា។ ប្រធានបទស្តីពី**ការការពារស្របច្បាប់**នេះប្រសូតឡើងក្រោមការណែនាំនិងតម្រង់ទិសពីលោកសាស្ត្រាចារ្យបណ្ឌិត ស៊ិន រិទ្ធ។

ការសម្រេចជ្រើសរើសយកប្រធានបទនេះមកសរសេរព្រោះយើងខ្ញុំយល់ឃើញថាប្រធានបទនេះមានសារៈសំខាន់ណាស់ចំពោះមនុស្សគ្រប់រូប និង ចំពោះសង្គមទាំងមូល ពោលគឺនឹងចូលរួមចំណែកជួយជាស្មារតីក្នុងការការពារដល់អាយុជីវិត សិទ្ធិសេរីភាពរបស់មនុស្ស ការពារដល់ទ្រព្យសម្បត្តិដែលជាកម្មសិទ្ធិរបស់រដ្ឋ របស់សមូហភាព និង របស់ឯកជនតាមរយៈនិក្ខេបបទនេះ។ ម្យ៉ាងទៀតករណីការការពារស្របច្បាប់នេះគឺជាការការពារដល់សិទ្ធិរបស់មនុស្សដែលត្រូវបានគាំពារដោយច្បាប់ជាតិ និង អន្តរជាតិជាច្រើន ប៉ុន្តែការការពារស្របច្បាប់នេះពុំទាន់មានចែងក្នុងច្បាប់របស់យើងនៅឡើយទេ (ពីឆ្នាំ១៩៧៩ ដល់ ២០០៣)។

**វិសាលភាពនៃប្រធានបទនេះលាតសន្ធឹងដល់ការការពារស្របច្បាប់និងស្ថានភាពចាំបាច់នៅព្រះរាជាណាចក្រកម្ពុជាពីឆ្នាំ១៩៧៩ដល់២០០៣**ហើយចំពោះការស្រាវជ្រាវលើប្រធានបទនេះគឺផ្តោតជាពិសេសទៅលើចំណុចសំខាន់ៗនៃការការពារខ្លួនតទល់ទៅនឹងបណ្តាអំពើរំលោភបំពានដោយអយុត្តិធម៌មកលើមនុស្ស និង បណ្តាផលប្រយោជន៍ដែលច្បាប់ការពារ ដោយអំពើរបស់ជនដែលតទល់វិញនោះត្រូវសមស្របតាមល័ក្ខខ័ណ្ឌច្បាប់ទើបរួចផុតពីការទទួលខុសត្រូវផ្នែកព្រហ្មទណ្ឌ ការការពារប្រភេទនេះគឺជា**ការការពារស្របច្បាប់ ឬ កិច្ចការពារជាធម្មានុរូប**។ ផ្ទុយទៅវិញ ប្រសិនបើអំពើរបស់ជនដែលតទល់វិញនោះលើសលប់ពេក ឬ មិនសមស្របតាមល័ក្ខខ័ណ្ឌច្បាប់ ការការពារប្រភេទនេះគឺជាការការពារមិនស្របច្បាប់ ឬ ការការពារជាអនីត្យានុកូល ហើយជននោះត្រូវទទួលខុសត្រូវផ្នែកព្រហ្មទណ្ឌជាកំណត់។ ចំណែកឯ**ស្ថានភាពចាំបាច់**វិញ គឺសំដៅដល់គ្រោះអាសន្នជាក់ស្តែងកំពុងគំរាមដល់បណ្តាផលប្រយោជន៍ដែលច្បាប់បានការពារ។បណ្តាផលប្រយោជន៍អាចជាផលប្រយោជន៍របស់រដ្ឋ-សង្គម-អាយុជីវិត-សុខភាពរូបកាយ ទ្រព្យសម្បត្តិ និង ផលប្រយោជន៍ផ្សេងទៀតរបស់មនុស្សដែលបានធ្វើសកម្មភាពក្នុងស្ថានភាពចាំបាច់ ឬ របស់ជនផ្សេងទៀត។ គ្រោះអាសន្នអាចកើតឡើងពីប្រភពផ្សេងៗជាច្រើនដូចជា : ដោយកម្លាំងរបស់ធម្មជាតិ ដោយមនុស្សបង្កឡើង ដោយសារភាពមិនប្រក្រតីនៃគ្រឿងម៉ាស៊ីន ដោយសារសត្វ។ល។ ការការពារខ្លួនតទល់ទៅនឹងបណ្តាគ្រោះអាសន្នខាងលើមកលើមនុស្ស និង បណ្តាផលប្រយោជន៍ដែលច្បាប់ការពារដោយអំពើរបស់ជនដែលតទល់វិញនោះត្រូវសមស្របតាមល័ក្ខខ័ណ្ឌច្បាប់ទើបរួចផុតពីការទទួលខុសត្រូវផ្នែកព្រហ្មទណ្ឌ។ផ្ទុយទៅវិញប្រសិនបើអំពើរបស់ជនដែលតទល់នោះមិនសមស្របតាមល័ក្ខខ័ណ្ឌច្បាប់ទេនោះ គឺជននោះត្រូវទទួលខុសត្រូវផ្នែកព្រហ្មទណ្ឌដូចករណីការការពារស្របច្បាប់ខាងលើដែរ។

ដោយសារតែឯកសារពាក់ព័ន្ធនឹងប្រធានបទនេះពុំសូវសំបូរបែប និង ពេលវេលាមានកំណត់ផងនោះទើបការស្រាវជ្រាវនេះនៅមានកម្រិត។ ទោះជាយ៉ាងនេះក្តី យើងខ្ញុំសង្ឃឹមថាស្នាដៃនេះក៏អាចចូលរួមចំណែកជាទុននៃពុទ្ធិជូនដល់ប្រិយមិត្តនិស្សិត និង ជនរួមជាតិយើងខ្លះដែរ។

សូមលោកអ្នកដែលស្រាវជ្រាវបន្តមេត្តាជួយបំពេញនូវកង្វះខាតនានា ដើម្បីឱ្យនិក្ខេបបទនេះកាន់តែមានភាពសុក្រឹត និង ផ្តល់នូវអត្ថប្រយោជន៍ច្រើនថែមទៀតដល់ប្រិយមិត្តនិស្សិត និង ជនរួមជាតិយើងនាពេលអនាគត។

# សេចក្ដីផ្ដើម

មនុស្សគ្រប់រូបត្រូវបានចាត់ទុកថាជាធនធានដ៏មានតម្លៃបំផុតរបស់សង្គម គឺជាមុខសញ្ញាសំខាន់ដែលត្រូវបានច្បាប់ព្រហ្មទណ្ឌ និង ច្បាប់ផ្សេងៗទៀតការពារ ។

ថ្វីត្បិតតែមានច្បាប់ជាច្រើនសម្រាប់ការពារអាយុជីវិត សិទ្ធិសេរីភាពរបស់មនុស្សយ៉ាងនេះហើយក៏ដោយ ក៏នៅមានអំពើខ្លះរបស់មនុស្សផ្ទុកទៅដោយគ្រោះថ្នាក់ដល់អាយុជីវិត សិទ្ធិសេរីភាពរបស់មនុស្ស និង គ្រោះថ្នាក់ដល់សង្គមផងដែរ ដែលអំពើទាំងនោះច្បាប់ហៅថាបទល្មើស ។

ទិដ្ឋភាពជាក់ស្ដែងនៅក្នុងសង្គម មានបណ្ដាអំពើតទល់ ឬ ការការពាររបស់មនុស្សដែលពិនិត្យលើរូបភាពខាងក្រៅមានរូបរាងដូចជាបទល្មើសដែលច្បាប់ព្រហ្មទណ្ឌបានចែង ក៏ប៉ុន្ដែអំពើនោះបានបំពេញតាមល័ក្ខខ័ណ្ឌដែលច្បាប់ព្រហ្មទណ្ឌទទួលស្គាល់ ហេតុនេះត្រូវបានច្បាប់ចាត់ទុកថាជាអំពើមានប្រយោជន៍ដល់សង្គម ជាអំពើស្របច្បាប់ ហើយជនដែលបានប្រព្រឹត្តអំពើនោះត្រូវរួចផុតពីការទទួលខុសត្រូវផ្នែកព្រហ្មទណ្ឌ។ តាមទស្សនៈច្បាប់របស់បណ្ដាប្រទេសមួយចំនួនបានហៅបណ្ដាល័ក្ខខ័ណ្ឌនោះថា ជាករណីបញ្ចៀសបាននូវចរិតគ្រោះថ្នាក់ដល់សង្គម និង ចរិតគ្រោះថ្នាក់នៃអំពើ ។

នៅក្នុងច្បាប់ព្រហ្មទណ្ឌដែលបច្ចុប្បន្នស្ថិតនៅជាធរមានក្នុងព្រះរាជាណាចក្រកម្ពុជា ជាពិសេសគឺច្បាប់ព្រហ្មទណ្ឌអន្ដរកាលចុះថ្ងៃទី១០ខែកញ្ញាឆ្នាំ១៩៩២ក៏ពុំមានចែងអំពីការការពារស្របច្បាប់នេះឡើយ ដោយឡែកមាត្រា៦៨ ចំណុចទី១ កថាខណ្ឌទី៤នៃច្បាប់នេះបានចែងដោយមិន ច្បាស់លាស់ថា*កាលៈទេសៈនៃអំពើឧក្រិដ្ឋ ឬ មជ្ឈិមដែលបណ្ដាលឱ្យអ្នកជាប់ទោសមានប្រតិកម្មដោយខានពុំបាន* ដែលជាស្ថានសម្រាលទោសតែប៉ុណ្ណោះ ។ តាមខ្លឹមសារនៃមាត្រាខាងលើ មានន័យថាក្នុងករណីដែលជនណាម្នាក់បានប្រព្រឹត្តនូវអំពើដែលច្បាប់បញ្ញត្តថាជាបទល្មើសទោះបីក្នុងកាលៈទេសៈណាក៏ដោយ ក៏ជននោះនៅតែទទួលខុសត្រូវផ្នែកព្រហ្មទណ្ឌជាដាច់ខាត ។

ដោយមើលឃើញនូវចំណុចខ្វះខាតរបស់ច្បាប់នៃព្រះរាជាណាចក្រកម្ពុជាយើងបច្ចុប្បន្ន និង ដើម្បីយុត្តិធម៌ក្នុងសង្គម ជាពិសេសដើម្បីជាការចូលរួមចំណែកក្នុងការអភិវឌ្ឍលើវិស័យច្បាប់របស់យើងផងនោះ ទើបជំរុញឱ្យយើងជ្រើសរើសយកប្រធានបទ **ការការពារស្របច្បាប់**នេះ មកធ្វើជាប្រធានបទនៃនិក្ខេបបទ ដើម្បីធ្វើការវិភាគ និង ឆ្លុះបញ្ចាំងទស្សនៈក្នុងច្បាប់សម្រាប់ការអនុវត្ត។ ប្រធានបទនេះ អាចជាចក្ខុវិស័យសម្រាប់ព្រះរាជាណាចក្រកម្ពុជាយើងបច្ចុប្បន្ន និង អនាគត ដោយផ្អែកលើក្រមព្រហ្មទណ្ឌសង្គមចាស់របស់ព្រះរាជាណាចក្រកម្ពុជាឆ្នាំ១៩៦៩ ក្រមព្រហ្មទណ្ឌរបស់ប្រទេសបារាំង និង ក្រមព្រហ្មទណ្ឌរបស់បណ្ដាប្រទេសជាច្រើនលើពិភពលោកផងដែរ ។

និក្ខេបបទនេះ ត្រូវបានចែកចេញជាពីរជំពូកគឺ : ជំពូកទី១ ការការពារខ្លួនស្របច្បាប់ និង ជំពូកទី២ ស្ថានភាពចាំបាច់ ។

ជំពូកទី១ បង្ហាញអំពីការតទល់ដោយស្របច្បាប់ចំពោះជនដែលកំពុងប្រព្រឹត្តអំពើរំលោភបំពានលើផលប្រយោជន៍ស្របច្បាប់ ពោលគឺបណ្តាផលប្រយោជន៍ដែលច្បាប់បានការពារ ដោយប្រើវិធីបង្កឱ្យមានការអន្តរាយចំពោះជនរំលោភបំពាននោះវិញ។ អំពើក្នុងការការពារខ្លួនស្របច្បាប់ អាចបង្កឱ្យមានការអន្តរាយណាមួយដល់ជនដែលបានប្រព្រឹត្តអំពើរំលោភបំពាននោះ ដើម្បីរារាំងទប់ស្កាត់នូវមហន្តរាយដែលអាចកើតមានដោយសារអំពើរបស់ជននោះ។ បើពិនិត្យអំពីរូបភាពខាងក្រៅឃើញថា អំពើរបស់ការការពារស្របច្បាប់នេះហាក់ដូចជាអំពើដែលច្បាប់បានបញ្ញត្តិថាជាបទល្មើស ប៉ុន្តែផ្ទុយមកវិញអំពើនេះត្រូវបានច្បាប់ចាត់ទុក និង ទទួលស្គាល់ថាជាអំពើស្របច្បាប់ជាអំពើដែលផ្តល់ផលប្រយោជន៍ដល់សង្គមទៅវិញ ហើយពុំត្រូវបានចាត់ទុកថាជាបទល្មើសឡើយ។ មានន័យថាការការពារខ្លួនស្របច្បាប់នេះ គឺជាសិទ្ធិរបស់មនុស្សគ្រប់រូបសម្រាប់ប្រើប្រាស់ក្នុងការទប់ទល់ចំពោះរាល់អំពើបំពានច្បាប់ឬរាល់អំពើដែលច្បាប់បានការពារ ក៏ប៉ុន្តែសិទ្ធិនេះអាចប្រើប្រាស់នៅក្នុងល័ក្ខខ័ណ្ឌជាកំណត់។ ការតទល់ដែលអ្នកតទល់បានប្រព្រឹត្តខុសពីល័ក្ខខ័ណ្ឌកំណត់នៃច្បាប់ព្រហ្មទណ្ឌបណ្តាលឱ្យមានការទទួលខុសត្រូវក្នុងបទព្រហ្មទណ្ឌ។

ជំពូកទី២ បង្ហាញអំពីការតទល់ក្នុងស្ថានភាពចាំបាច់ នៅពេលដែលមានអំពើបង្កមហន្តរាយកើតឡើង គឺដើម្បីការពារបាននូវផលប្រយោជន៍ស្របច្បាប់ណាមួយនោះ មនុស្សពុំអាចជ្រើសរើសបាននូវវិធីណាផ្សេងក្រៅពីបង្កឱ្យមានការអន្តរាយដល់ផលប្រយោជន៍ស្របច្បាប់ណាមួយផ្សេងទៀត។ ក្នុងស្ថានភាពជាក់ស្តែងនេះការបង្កនូវមហន្តរាយ គឺជាវិធីតែមួយគត់ និង ចុងក្រោយ សំដៅជំនះបាននូវគ្រោះអាសន្នដែលកំពុងគំរាមកំហែង។ ការប្រព្រឹត្តអំពើរបស់មនុស្សក្នុងស្ថានភាពចាំបាច់នេះ បើពិនិត្យអំពីរូបភាពខាងក្រៅឃើញមានការស្តែងចេញដូចជាអំពើល្មើសច្បាប់ព្រហ្មទណ្ឌ ប៉ុន្តែដោយសារការទប់ស្កាត់បាននូវមហន្តរាយធំមួយនោះ អំពើនេះត្រូវបានចាត់ថាជាអំពើមានប្រយោជន៍សម្រាប់សង្គម។ បណ្តាសកម្មភាពបែបនេះត្រូវបានច្បាប់ចាត់ទុកថាជាអំពើស្របច្បាប់ ដូចនេះជនប្រព្រឹត្តអំពើ ពុំត្រូវទទួលខុសត្រូវផ្នែកព្រហ្មទណ្ឌឡើយ ក៏ប៉ុន្តែអំពើតទល់នេះត្រូវប្រើប្រាស់ស្របតាមល័ក្ខខ័ណ្ឌកំណត់។ ការតទល់ដែលអ្នកតទល់បានប្រព្រឹត្តខុសពីល័ក្ខខ័ណ្ឌកំណត់នៃច្បាប់ព្រហ្មទណ្ឌ បណ្តាលឱ្យមានការទទួលខុសត្រូវក្នុងបទព្រហ្មទណ្ឌ។

ក្នុងនិក្ខេបបទនេះ យើងសូមលើកយកមកសិក្សានូវករណីមួយចំនួនដែលបច្ចុប្បន្នត្រូវបានទស្សនៈនៃនីតិព្រហ្មទណ្ឌទទួលស្គាល់ថាជាការការពារខ្លួនស្របច្បាប់ និង ស្ថានភាពចាំបាច់។ បញ្ហាសំខាន់ក្នុងនិក្ខេបបទនេះគឺ ៖

-តើអំពើបែបណាដែលច្បាប់ចាត់ទុកថាមានប្រយោជន៍ដល់សង្គម និង ចាត់ទុកថាជាការការពារខ្លួនស្របច្បាប់ ឬ ស្ថានភាពចាំបាច់?

-តើអំពើទាំងនេះមានចែងក្នុងច្បាប់របស់ព្រះរាជាណាចក្រកម្ពុជាយើងទេ?

-តើរាជរដ្ឋាភិបាលគួរប្រកាន់ជំហរបែបណា?

ឯការសិក្សាស្រាវជ្រាវប្រធានបទនេះ ជាចម្បងគឺ ត្រូវចេះប្រមែប្រមូលបញ្ហាស្មារតី ហើយផ្ដោតអារម្មណ៍ឆ្ពោះទៅលើបណ្ដាឯកសារទាំងឡាយណាដែលពាក់ព័ន្ធទៅនឹងអំពើតទល់ចំពោះរាល់អំពើរំលោភបំពានដែលបង្កឱ្យមានការអន្តរាយ ឬ គំរាមបង្កឱ្យមានការអន្តរាយដល់បណ្ដាផលប្រយោជន៍ដែលច្បាប់បានការពារ។

លំដាប់នៃការស្រាវជ្រាវ មានដូចជា :-ការជ្រើសរើសប្រធានបទ-ការកំណត់បញ្ហា-ការកំណត់គោលដៅនៃការស្រាវជ្រាវ-តម្រូវការទិន្នន័យ-ការរៀបចំវិធីសាស្ត្រនិងឧបករណ៍ស្រាវជ្រាវ-ការធ្វើផែនការប្រមូលទិន្នន័យ-ការវិភាគទិន្នន័យ-ការរៀបចំ និង សរសេរកិច្ចការ និង សេចក្ដីសន្និដ្ឋាន។

កម្មវត្ថុនៃការសិក្សាគឺ : ធ្វើការអង្កេត និង វិភាគស៊ីជម្រៅលើរាល់ចំណោទបញ្ហានីមួយៗដែលបានលើកឡើងនៅក្នុងប្រធានបទ។ ការសិក្សាផ្ដោតសំខាន់ទៅលើអំពើតទល់ណាដែលច្បាប់មិនយកទោសពៃរ៍ ពោលគឺជាការការពារខ្លួនស្របច្បាប់ និង ស្ថានភាពចាំបាច់។

គោលដៅនៃការសិក្សា គឺសិក្សាអំពី :-អត្ថន័យទូទៅនៃការការពារស្របច្បាប់-ល័ក្ខខ័ណ្ឌនៃការការពារខ្លួនស្របច្បាប់-អត្ថន័យទូទៅនៃស្ថានភាពចាំបាច់-ល័ក្ខខ័ណ្ឌនៃស្ថានភាពចាំបាច់ និង ការផ្ដោតទស្សនៈផ្ទាល់ខ្លួន។

វិធីសាស្ត្រសម្រាប់ប្រមូលទិន្នន័យគឺ :

-បណ្ដាឯកសារដែលប្រមូលបាន ត្រូវរៀបចំវាទៅតាមលំដាប់ថ្នាក់ ដើម្បីជាការងាយស្រួលក្នុងការចាប់យកមកសរសេរចៀសវាងការខាតបង់ពេលវេលា

-រៀបចំចំណាត់ថ្នាក់ឯកសារទៅតាមជំពូកនីមួយៗ

-រៀបចំ Fiches សម្រាប់កត់ត្រាដើម្បីងាយស្រួលក្នុងការចំណាំពេលប្រើប្រាស់ Footnote

-រៀបចំឧបករណ៍សម្រាប់ប្រមូលទិន្នន័យជាអាទិ៍ :ម៉ាស៊ីនថតសំឡេង ម៉ាស៊ីនថតរូប ខ្មៅដៃ ប៊ិកសរសេរ ប៊ិកពណ៌ ក្រដាស សៀវភៅ។ល។

-ការប្រមូលទិន្នន័យ គឺធ្វើទៅតាមវិធីសាស្ត្រ វិភាគស៊ីជម្រៅ និង ការប្រើសំណួរជាគន្លឹះ